CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១២ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចចេញបទបញ្ជាសុខភាពដែលត្រូវបានកែប្រែ

*អនុញ្ញាតឱ្យបង្កើនសកម្មភាពនៅឆ្នេរនិងឧទ្យាន, អាជីវកម្មបន្ថែមនឹងអាចបើក*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះមន្ទីរសុខាភិបាលនិងសេវាប្រជាជននៃទីក្រុងឡុងប៊ិចបានចេញបទបញ្ជា "រក្សាសុវត្ថិភាពដោយនៅផ្ទះ" ដែលត្រូវបានកែប្រែដែលនឹងអនុញ្ញាតការប្រើប្រាស់កន្លែងកម្សាន្តក្នុងទីក្រុងកាន់តែទូលំទូលាយដែលរួមមានសកម្មភាពដែលនៅនឹងមួយកន្លែងនៅតាមមាត់សមុទ្រនិងសួនឧទ្យានដោមសមាជិកនៃគ្រួសារតែមួយ។ ទីលានកីឡាដូចជាទីលានបាល់បោះនិងទីលានបាល់ទះគឺមានសម្រាប់សមាជិកនៃគ្រួសារតែមួយ។ ការកែប្រែទាំងនេះគឺបន្ថែមពីលើសេចក្តីប្រកាសកាលពីថ្ងៃពុធដែលស្តីពីអាជីវកម្មបន្ថែមដែលត្រូវបានអនុញ្ញាតឱ្យបើកដំណើរការឡើងវិញដោយមានការដាក់កម្រិតខ្លះ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "នៅពេលដែលយើងត្រលប់ទៅទម្លាប់ប្រចាំថ្ងៃរបស់យើងវិញគឺជាការសំខាន់ណាស់ដែលយើងត្រូវចងចាំថាមេរោគកូរ៉ូណានេះគឺជាភាពអាសន្នផ្នែកសុខភាពសាធារណៈ។ នេះមានន័យថាយើងនៅតែត្រូវអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នានិងមានការទទួលខុសត្រូវចំពោះការពាក់របាំងមុខដើម្បីយើងអាចបន្តការបើកឡើងវិញទាំងនេះតទៅទៀត។"

បទបញ្ជារក្សាសុវត្ថិភាពដោយនៅផ្ទះដែលត្រូវបានកែប្រែគឺមាននៅទីនេះ។

ចាប់ពីថ្ងៃទី ១២ ខែមិថុនាក្នុងចំណោមការផ្លាស់ប្តូរផ្សេងទៀតដែលមានចែងនៅក្នុងបទបញ្ជាបុគ្គលនិងសមាជិកនៃគ្រួសារតែមួយអាចទៅឆ្នេរសមុទ្រសាធារណៈនិងឧទ្យាននានាហើយៈ

- ចូលរួមក្នុងសកម្មភាពដែលនៅនឹងមួយកន្លែង (ជាឧទាហរណ៍ការគេងហាលថ្ងៃ ការអង្គុយនិងការញ៉ាំអាហារ) និងការកំសាន្តនិងហាត់ប្រាណខាងក្រៅយ៉ាងសកម្មឱ្យតែលោកអ្នករក្សាចម្ងាយរាងកាយយ៉ាងហោចណាស់ប្រាំមួយហ្វីតពីសមាជិកនៃគ្រួសារផ្សេងទៀត។
- ប្រើទីធ្លាបាល់បោះទីលានបាល់ទះទីលានលេងតិនីសនិងកន្លែងញ៉ាំអាហារដោយមានការកំណត់សកម្មភាពត្រឹមតែគ្រួសារមួយក្នុងពេលតែមួយតែប៉ុណ្ណោះ។ ការលេងល្បែងជាមួយអ្នកដទៃក្រៅពីសមាជិកគ្រួសាររបស់លោកអ្នករួមទាំងការលេងកីឡាជាក្រុមនៅតែត្រូវហាមឃាត់។

ការជួបជុំគ្នាឬសកម្មភាពដែលពាក់ព័ន្ធនឹងគ្រួសារច្រើនជាងមួយនៅតែត្រូវហាមឃាត់ក្រោមបទបញ្ជាសុខភាព។

លើសពីនេះបទបញ្ជាដែលបានធ្វើវិសោធនកម្មនេះក៏អនុញ្ញាតិឱ្យអាជីវកម្មមួយចំនួនដូចជាកន្លែងហាត់ប្រាណ កម្មវិធីជំរុំពេលថ្ងៃសំរាប់យុវជន សារមន្ទី រអាងចិញ្ចឹមត្រី Aquarium of the Pacific និងសណ្ឋាគារបើកដំណើរការឡើងវិញនៅថ្ងៃទី ១២ ខែមិថុនានៅពេលពួកគេបានបំពេញនូវតម្រូវការសុវត្ថិភាពចាំបាច់។ វិធានការអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នានិងការពាក់របាំងមុខគឺជាសកម្មភាពដែលត្រូវបានលើកទឹកចិត្តឱ្យអនុវត្តនិង / ឬជាតម្រូវការដែលត្រូវអនុវត្ត។ បញ្ជីពេញលេញនៃឈ្មោះអាជីវកម្មនិងពិធីសារសុវត្ថិភាពដែលបានតម្រូវគឺមាននៅក្នុងកំណែចុងក្រោយនៃបទបញ្ជាសុខភាព។

អាជីវកម្មដូចជាហាងធ្វើក្រចក  ហាងសាក់លើស្បែក ហាងស្ប៉ានិងហាងធ្វើម៉ាស្សា បារ ហាងលក់ស្រាបៀរនិងស្រាទំពាំងបាយជូរដែលមិនបម្រើអាហារ កន្លែងកម្សាន្តជាលក្ខណៈគ្រួសារ (ជាឧទាហរណ៍កន្លែងបោះប៊ូល កន្លែងលេងល្បែងអេកខែតសម្រាប់កុមារ រោងកុន) និងកន្លែងលេងល្បែងនានានៅតែត្រូវបិទ។

មន្ទីរសុខាភិបាលនិងសេវាប្រជាជននៃទីក្រុងឡុងប៊ិចកំពុងតាមដានទិន្នន័យជំងឺរាតត្បាតក្នុងរយៈពេល ២ ទៅ ៣ សប្តាហ៍ខាងមុខដើម្បីកំណត់ថាតើត្រូវបើកអាជីវកម្មបន្ថែមដែលរំពឹងថានឹងត្រូវអនុញ្ញាត

ដោយអភិបាលរដ្ឋ Gavin Newsom ដែរឬទេដែលការបើកទាំងនេះគឺជាផ្នែកមួយនៃការបើកឡើងវិញដំណាក់កាលទី ៣ របស់រដ្ឋ។ អាជីវកម្មទាំងនោះគឺរួមមានបារ កន្លែងកម្សាន្តជាលក្ខណៈគ្រួសារនិងហាងផ្តល់សេវាកម្មផ្ទាល់ខ្លួន (ជាឧទាហរណ៍ការធ្វើក្រចកដៃ ការធ្វើក្រចកជើង ការសាក់លើស្បែក ការធ្វើម៉ាស្សា និងសេវាកម្មដករោមដោយប្រើក្រមួន)។ នៅពេលដែលសេចក្តីណែនាំថ្មីរបស់រដ្ឋត្រូវបានប្រកាសដោយអភិបាលរដ្ឋរាល់ឃ្លានីមួយៗនឹងត្រូវវាយតម្លៃដោយឡែកហើយនឹងអាចឬមិនអាចត្រូវបានអនុវត្តនៅឡុងប៊ិចដោយផ្អែកលើសេចក្តីសំរេចរបស់មន្ត្រីសុខាភិបាលនៃទីក្រុង។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាម អំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។ បទបញ្ជានេះមានប្រសិទ្ធភាពភ្លាមៗនៅថ្ងៃទី ១២ ខែមិថុនាឆ្នាំ ២០២០ ហើយនឹងបន្តរហូតដល់មានការពន្យារពេលដកហូតឬកែប្រែជាលាយលក្ខណ៍អក្សរដោយមន្ត្រីសុខាភិបាល។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #